# ព្រះរតនត្រ័យ

ព្រះរតនត្រ័យ　　　　វិសេសថ្លៃបីប្រការ
ដែលមនុស្សនិងទេព្តា　　　　តែងបូជាគ្រប់ទីឋាន ។
ទីមួយព្រះសម្ពុទ្ធ　　　　បញ្ញាមុតអនន្តញ្ញាណ
ព្រះធម៌ទុកដូចយាន　　　　នាំសត្វបានជាទីពីរ
ព្រះសង្ឃបរិសុទ្ធ　　　　វិសេសផុតស្ងប់ឥន្ទ្រិយ
ជួយអង្គព្រះមុនី　　　　គ្រប់ទិសទីជាទីបី ។
អ្នកដល់រតនត្រ័យ　　　　ផុតទុក្ខភ័យមានសិរី
ចាប់តាំងពីលោកិយ　　　　រៀងដរាបដល់និព្វាន ។
កុំគប្បីប្រមាទ　　　　ត្រូវសង្វាតខំសូត្ររៀន
ធម៌អាថ៌ព្រះទ្រង់ញាណ　　　　កុំបីខានគ្រប់ ៗ គ្នា ។
នាំគ្នាបដិបត្តិ　　　　រៀងរាល់រត្តិន្ទិវា
ជោគជ័យសិរីសុខា　　　　ឈ្នះមារាគ្រប់គ្នាហោង៕

**ចាក ព្រះរតនត្រ័យ ឆ្នាំ ១៩៩៤**